ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ
លេខ ០០២/២៤ សលទ.អ.ជ.ក.

# សេចក្តីសម្រេច
# ស្តីពី
# បែបបទ នីតិវិធី និងគុណវុឌ្ឍិសម្រាប់ការផ្តល់នីតិសម្បទាជាមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

## អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៣/២៣៨១ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីការបង្កើត ការរៀបចំ និងកិច្ចដំណើរការរបស់អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ
- បានឃើញអនុក្រឹត្យលេខ ៣៤១ អនក្រ.បក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ
- យោងតាមស្មារតីនៃកិច្ចប្រជុំអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ នាសម័យប្រជុំថ្ងៃទី៨ ខែមករា ឆ្នាំ២០២៤

## សម្រេច

### ប្រការ១.-

សេចក្តីសម្រេចនេះកំណត់អំពីបែបបទ នីតិវិធី និងគុណវុឌ្ឍិសម្រាប់ការផ្តល់នីតិសម្បទាជាមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (**អ.ជ.ក.**)។

### ប្រការ២.-

ការជ្រើសរើសមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃ **អ.ជ.ក.** ស្របតាមប្រការ៣ នៃសេចក្តីសម្រេចនេះ ត្រូវធ្វើឡើងដោយគណៈកម្មការមួយ ដែលត្រូវបង្កើតឡើងដោយ **អ.ជ.ក.**។ គណៈកម្មការនេះត្រូវកំណត់អំពីលក្ខខណ្ឌ បែបបទ និងនីតិវិធីលម្អិតនៃការជ្រើសរើសមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ ដោយអនុវត្ត



មហាវិថីឈ្នះឈ្នះ ភូមិព្រែកតាវ័ន្ត សង្កាត់ព្រែកតាសេក ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ Email: nadr@moj.gov.kh

ស្របតាមព្រះរាជក្រឹត្យស្តីពីការបង្កើត ការរៀបចំ និងកិច្ចដំណើរការរបស់អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និងសេចក្តីសម្រេចនេះ។

ចំនួនមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទដែលត្រូវជ្រើសរើស ត្រូវកំណត់ដោយ **អ.ជ.ក.**។

**ប្រការ៣ ..**

បេក្ខជនដែលអាចត្រូវបានជ្រើសរើសជាមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃ **អ.ជ.ក.** ស្របតាមប្រការ ២ នៃសេចក្តីសម្រេចនេះ ត្រូវមានគុណវុឌ្ឍិដូចខាងក្រោម៖

១- មានសញ្ជាតិខ្មែរ

២- មានអាយុយ៉ាងតិច ២៥ ឆ្នាំ

៣- មានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រច្បាប់ឡើងទៅ

៤- មិនធ្លាប់ត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬបទមជ្ឈិមដោយចេតនាដោយគ្មានការលើកលែងទោស។

បុគ្គលដែលត្រូវបានជ្រើសរើសជាមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ ត្រូវទទួលបាននូវការបណ្តុះ-បណ្តាលវិជ្ជាជីវៈ ស្របតាមព្រះរាជក្រឹត្យស្តីពីការបង្កើត ការរៀបចំ និងកិច្ចដំណើរការរបស់អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។

មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទដែលបានបញ្ចប់ការបណ្តុះបណ្តាលដោយជោគជ័យ ត្រូវទទួលបានវិញ្ញាបនបត្រជំនាញសម្រុះសម្រួលដោះស្រាយវិវាទ ដែលចេញដោយក្រសួងយុត្តិធម៌។

**ប្រការ៤ ..**

**អ.ជ.ក.** អាចផ្តល់នីតិសម្បទាជាមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ ដល់បុគ្គលដែលមានសញ្ជាតិខ្មែរ និងមានគុណវុឌ្ឍិណាមួយដូចខាងក្រោម៖

ក-បុគ្គលដែលមានវិញ្ញាបនបត្របណ្តុះបណ្តាលជំនាញសម្រុះសម្រួលដោះស្រាយវិវាទ ដែលចេញដោយក្រសួងយុត្តិធម៌។

ខ-បុគ្គលដែលមិនធ្លាប់ត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬបទមជ្ឈិមដោយចេតនា ដោយគ្មានការលើកលែងទោស ឬផ្តន្ទាទោសជាបទវិន័យ ឬជាបទរដ្ឋបាលដូចជា ការលុបឈ្មោះ ការបញ្ឈប់ពីមុខងារ ការហូតងារដោយមូលហេតុប្រព្រឹត្តអំពើផ្ទុយនឹងកិត្តិយស ឬអំពើមិនស្អាតស្អំ និងមានគុណវុឌ្ឍិណាមួយ ដូចតទៅ៖

- អតីតចៅក្រម អតីតព្រះរាជអាជ្ញា អតីតក្រឡាបញ្ជី ឬអតីតអាជ្ញាសាលា ដែលបានប្រកបវិជ្ជាជីវៈរយៈពេលយ៉ាងតិច ៣ ឆ្នាំ។

- មេធាវី ឬសារការី ដែលបានប្រកបវិជ្ជាជីវៈ រយៈពេលយ៉ាងតិច ៣ ឆ្នាំ។

- សមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាល ឬមជ្ឈត្តករ ដែលមានបទពិសោធន៍ការងារដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ រយៈពេលយ៉ាងតិច ៣ ឆ្នាំ។

- ឥស្សរជន ឬមន្ត្រីសាធារណៈ ដែលមានបទពិសោធន៍ការងារពាក់ព័ន្ធនឹងការដោះស្រាយវិវាទ រយៈពេលយ៉ាងតិច ៣ ឆ្នាំ។

- បុគ្គលដែលមានសញ្ញាបត្រ ឬវិញ្ញាបនបត្រជំនាញសម្រុះសម្រួលដោះស្រាយវិវាទ ដែលទទួលស្គាល់ដោយក្រសួងយុត្តិធម៌។

- បុគ្គលដែលមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រឡើងទៅ និងមានបទពិសោធន៍ការងារពាក់ព័ន្ធនឹងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ រយៈពេលយ៉ាងតិច ៣ ឆ្នាំ។

**ប្រការ៥ ..**

ដើម្បីទទួលបាននីតិសម្បទាជាមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃ **អ.ជ.ក.,** បុគ្គលដែលមានគុណវុឌ្ឍិណាមួយដូចមានកំណត់ក្នុងប្រការ ៤ នៃសេចក្ដីសម្រេចនេះ ត្រូវដាក់ពាក្យស្នើសុំមក **អ.ជ.ក.** តាមរយៈអគ្គលេខាធិការដ្ឋាននៃ **អ.ជ.ក.**។ អគ្គលេខាធិការដ្ឋាននៃ **អ.ជ.ក.** ត្រូវលើកសំណើជូន **អ.ជ.ក.** ដើម្បីពិនិត្យ និងសម្រេចលើសំណើសុំនីតិសម្បទាជាមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ។

មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទដែលទទួលបាននីតិសម្បទា ស្របតាមចំណុច ខ នៃប្រការ៤ នៃសេចក្ដីសម្រេចនេះ អាចទទួលបាននូវការបណ្ដុះបណ្ដាលតម្រង់ទិស ដោយផ្អែកតាមតម្រូវការចាំបាច់ស្របតាមព្រះរាជក្រឹត្យស្ដីពីការបង្កើត ការរៀបចំ និងកិច្ចដំណើរការរបស់អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។ មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទដែលបានបញ្ចប់ការបណ្ដុះបណ្ដាលតម្រង់ទិស ត្រូវទទួលបានវិញ្ញាបនបត្រជំនាញសម្រុះសម្រួលដោះស្រាយវិវាទ ដែលចេញដោយក្រសួងយុត្តិធម៌។

**ប្រការ៦ ..**

ក្រោយទទួលបាននីតិសម្បទាពី **អ.ជ.ក.** មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃ **អ.ជ.ក.** ត្រូវធ្វើសច្ចាប្រណិធាន ដែលរៀបចំដោយក្រសួងយុត្តិធម៌ មុននឹងអនុវត្តមុខងាររបស់ខ្លួន។ ខ្លឹមសារនៃសច្ចាប្រណិធានមានភ្ជាប់ជាឧបសម្ព័ន្ធនៃសេចក្ដីសម្រេចនេះ។

**ប្រការ៧ ..**

មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ ដែលត្រូវបានជ្រើសរើស និងបានទទួលនីតិសម្បទាពី **អ.ជ.ក.** ត្រូវស្ថិតនៅក្រោមលក្ខន្តិកៈរបស់មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃ **អ.ជ.ក.** ដែលត្រូវកំណត់ដោយសេចក្ដីសម្រេចដោយឡែករបស់ **អ.ជ.ក.**។

**ប្រការ៨ ..**

មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទដែលបានទទួលនីតិសម្បទាពី **អ.ជ.ក.** ត្រូវបំពេញមុខងាររបស់ខ្លួនតាមការចាត់តាំង និងក្រោមការត្រួតពិនិត្យពី **អ.ជ.ក.**។

**ប្រការ៩ ..**

មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃ **អ.ជ.ក.** ត្រូវទទួលខុសត្រូវចំពោះកិច្ចការដែលបានប្រគល់ឱ្យ និងត្រូវបំពេញមុខងាររបស់ខ្លួនឱ្យបានម៉ឺងម៉ាត់ ដោយត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ព្រមទាំងក្រមសីលធម៌ និងក្រមប្រតិបត្តិរបស់មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទដែលត្រូវកំណត់ដោយ **អ.ជ.ក.**។

មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃ **អ.ជ.ក.** ដែលបំពានច្បាប់ លិខិតបទដ្ឋានគតិយុត្តជាធរមាន ក្រមសីលធម៌ ឬក្រមប្រតិបត្តិរបស់មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃ **អ.ជ.ក.** ក្នុងការបំពេញមុខងាររបស់ខ្លួន ត្រូវទទួលទណ្ឌកម្មរដ្ឋបាល ដែលរួមមាន ការស្តីបន្ទោស ការព្យួរ ឬការដកហូតនីតិសម្បទា។ ក្នុងករណីនេះ អគ្គលេខាធិការដ្ឋាននៃ **អ.ជ.ក.** ត្រូវលើកសំណើជូន **អ.ជ.ក.** ពិនិត្យ និងសម្រេចអំពីទណ្ឌកម្មរដ្ឋបាលណាមួយចំពោះមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃ **អ.ជ.ក.** ដែលបានប្រព្រឹត្តកំហុសក្នុងការបំពេញមុខងាររបស់ខ្លួន។

ការសម្រេចដាក់ទណ្ឌកម្មរដ្ឋបាលខាងលើ មិនមែនជាឧបសគ្គសម្រាប់ការចោទប្រកាន់ និងការផ្តន្ទាទោសព្រហ្មទណ្ឌ ព្រមទាំងការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមានផ្សេងទៀតនោះទេ។

លក្ខខណ្ឌ បែបបទ និងនីតិវិធីលម្អិតនៃការដាក់ទណ្ឌកម្មរដ្ឋបាលចំពោះមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃ **អ.ជ.ក.** ត្រូវកំណត់ដោយសេចក្តីសម្រេចដោយឡែករបស់ **អ.ជ.ក.**។

## **ប្រការ១០.-**

អនុប្រធាន និងសមាជិកនៃ **អ.ជ.ក.** អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាននៃ **អ.ជ.ក.** និងមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃ **អ.ជ.ក.** ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ២កើត ខែ បុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែមករា ឆ្នាំ២០២៤

**ជ. អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**និងជាប្រធាន អ.ជ.ក.**

**កើត រិទ្ធ**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងយុត្តិធម៌
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ១០
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធនៃសេចក្តីសម្រេចលេខ ០០២/២៤ សសរ.អ.ជ.ក. ចុះថ្ងៃទី ១២ ខែមករា ឆ្នាំ២០២៤**

## ខ្លឹមសារសច្ចាប្រណិធាន
## មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃ អ.ជ.ក.

ក្នុងពេលបំពេញមុខងារជាមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ ខ្ញុំសូមប្តេជ្ញាថា ខ្ញុំនឹងប្រតិបត្តិនូវតួនាទី និងភារកិច្ចរបស់ខ្លួន ក្នុងឋានៈជាមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ ដោយគោរពឱ្យបានម៉ឺងម៉ាត់ និងត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញ និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងក្រមសីលធម៌ ក្រមប្រតិបត្តិ និងវិធាននានាដែលចេញដោយអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។ ខ្ញុំសូមសច្ចាថា ខ្ញុំនឹងស្មោះត្រង់ចំពោះវិជ្ជាជីវៈ ប្រកាន់ខ្ជាប់នូវឧត្តមគតិជាតិ និងតម្កល់ផលប្រយោជន៍របស់គូភាគីវិវាទ ព្រមទាំងបំពេញមុខងាររបស់ខ្លួនប្រកបដោយភាពអព្យាក្រឹត្យ សេចក្តីថ្លៃថ្នូរ សុចរិតភាព និងសតិសម្បជញ្ញៈខ្ពស់ ដើម្បីធានាបាននូវភាពសុខដុមរមនា និងយុត្តិធម៌ក្នុងសង្គមជាតិ។